# ស្វែងរកការពិត

អ្នកនិពន្ធៈ ខេល្លី ហៃឌ្រិច

ប្រែសម្រួលដោយៈ សើ សាយ្យាណា

តួអង្គៈ

១) សាវរីៈ តួអង្គនេះគួរតែជាស្ត្រីសាមញ្ញទៅម្នាក់ មានសំលៀកបំពាក់និងមុខមាត់ធម្មតា (មិនបាច់សម្តែងទឹកមុខខ្លាំងពេកទេ តិចៗបានហើយ មិនចង់ឲ្យពាក់របាំងមុខ ព្រោះគង់តែត្រូវពាក់នៅពេលក្រោយនៅតុលាការ) ។ គាត់ពាក់សម្លៀកបំពាក់រលុងពណ៌បៃតង ដែលអាចធ្វើឲ្យនឹកឃើញដល់សម្លៀកបំពាក់ខ្មែរក្រហម ។

២) ចៅក្រមស៊ើបអង្កេតទី១ និង ចៅក្រមស៊ើបអង្កេតទី២ៈ ទាំងពីរនាក់នេះ ត្រូវធ្វើការជាក្រុមមួយ ប៉ុន្តែចៅក្រមទី១តែងតែនៅក្រោមចៅក្រមទី២ជានិច្ច ដូចជា មើល ធ្វើតាម ស្តាប់តាមការដឹកនាំរបស់ចៅក្រមទី២ ។ ចៅក្រមទី១ គួរតែមានកាន់ផែនទី បញ្ជី និង សៀវភៅច្បាប់ ។

៣) មេធាវីការពារក្តី (ស្នាក្តី)

៤) ព្រះរាជអាជ្ញា

៥) ចៅក្រមកាត់ក្តី

៦) ចុងចោទៈ អ្នកជាប់ចោទគឺជាអង្គការ ។ គាត់គួរតែពាក់របាំងមុខរូបក្អែកប្រុស្នាត និងឯកសណ្ឋានពណ៌ខ្មៅ ចាស់រហែក ។

**ឈុតទី១:** *ខេត្ត តាកែវ ។ សហចៅក្រមស៊ើបអង្កេតទាំងពីរ ក្នុងឯកសណ្ឋានជាចៅក្រម (រ៉ូបពណ៌ខ្មៅ) កំពុងមើលផែនទី ពិគ្រោះគ្នា ។*

សហចៅក្រមទី១ៈ មិញ គេថាត្រូវបត់ផ្លូវណា?

សហចៅក្រមទី២ៈ បត់ផ្លូវហ្នឹង

សហចៅក្រមទី១ៈ ឈប់សិនមើល៍ ។ ផ្លូវទី១ឬទី២? ខ្ញុំគិតថា យើងត្រូវបត់នៅផ្លូវទី១ ។ យើងគួរតែត្រឡប់ទៅក្រោយវិញ ។

សហចៅក្រមទី២ៈ ផ្លូវទី១ទៅមិនរួចទេត្រូវបិទហើយ ចាំអត់? អ៊ីចឹង យើងក៏បត់តាមផ្លូវទី២ រួចត្រឡប់ទៅតាមផ្លូវមុនវិញទៀត ។

សហថៅក្រមទី១៖ យ៉ឺ យើងកំពុងរកអ្នកណាហ្នឹង?

*ទាំងពីរនាក់ស្ងាត់មាត់បន្តិច ។ សហថៅក្រមទី២យកបញ្ជីមួយចេញមក ។*

សហថៅក្រមទី២៖ អា៎ នេះ សាក្សីឈ្មោះ សាវរី ។

សហថៅក្រមទី១៖ ហ្នឹងហើយដែលខ្ញុំបានគិតនោះ ។ (ស្ងាត់បន្តិច) យើងគ្មានផ្លូវរកគាត់ឃើញទេ ។

សហថៅក្រមទី២៖ ពួកយើងត្រូវតែរកគាត់ ។ (ស្ងាត់បន្តិច) ហ្នឹងគឺជាការងាររបស់យើង ។

សហថៅក្រមទី១៖ ត្រឹមត្រូវហើយ ។ (ស្ងាត់បន្តិច) អ៊ីចឹង យើងកំពុងតែរកអ្នកណា?

សហថៅក្រមទី២ (កំពុងមើលក្រដាសរបស់គាត់)៖ សាក្សីឈ្មោះ សាវរី ។

សហថៅក្រមទី១៖ ត្រូវហើយ ។ ខ្ញុំគ្រាន់តែភ្លេចមួយភ្លែតតែប៉ុណ្ណោះ ។

សហថៅក្រមទី២៖ ហ្នឹងហើយ ។

សហថៅក្រមទី១៖ ព្រោះយើងសម្ភាសមនុស្សច្រើនណាស់ ។

សហថៅក្រមទី២៖ អ៊ីចឹងមែនហើយ ។ ការស៊ើបអង្កេតគឺជារឿងធ្វើឲ្យនឿយហត់ ។

សហថៅក្រមទី១៖ ខ្ញុំដូចជាហត់ អស់កម្លាំងហើយ ។ យើងគួរតែត្រឡប់ទៅការិយាល័យវិញតែម្ដងទៅ ។

សហថៅក្រមទី២៖ យើងគួរតែឈប់សំរាកមួយសន្ទុះសិនទៅ ។

*ថៅក្រមទាំងពីរ អង្គុយ ស្ងាប ហើយក៏បិទភ្នែកដេក ។ សាវរីដើរចូលមកពីខាងស្ដាំ ។ គាត់ឃើញសហថៅក្រមទាំងពីរ ក៏ឈប់ ។ គាត់មើលជុំវិញ រួចក្រហេម ។ ថៅក្រមទាំងពីរដែលកំពុងតែស្រមុក ភ្ញាក់ដឹងខ្លួន រកមើលសម្លេង ហើយឃើញសាវរី ក៏ចាប់ផ្ដើមមើលផែនទីនិងបញ្ជីរបស់ពួកគាត់ទាំងមមីងមមាំង ។*

សហថៅក្រមទី១ (និយាយខ្លាំងៗដើម្បីឲ្យសាវរីឮ)៖ អ៊ីចឹង ខ្ញុំជឿថា ប្រសិនបើបន្តទៅតាមផ្លូវនេះទៀត យើងគួរតែរកសាក្សីដែលយើងកំពុងរកនោះ ឃើញហើយ ។ ប្រហែលជាយើងត្រូវសួរអ្នកណាម្នាក់ដែលយើងជួបតាមផ្លូវ ។

*សាវរីធ្វើចិញ្ចើមឡើងលើ ហើយដើរតម្រង់មកថៅក្រម ។*

*សារ៉ារី៖ លោកដូចជាវង្វេងផ្លូវ ។ លោកមានការរកអីដែរ?*

*សហចៅក្រមទី២ (ធ្វើវាងក្រអើត)៖ ពួកខ្ញុំដឹងច្បាស់ណាស់ថាកំពុងតែរកអ្នកណា ។*

*សហចៅក្រមទី១៖ មែនហើយ ។ ពួកខ្ញុំដឹងថាកំពុងរកអ្នកណា ។ គ្រាន់តែមិនដឹងកន្លែងណា ។*

*សហចៅក្រមទី២៖ ពិតមែ...ទេ យើងដឹងថាគាត់នៅឯណា ។ យើងគ្រាន់តែមិនដឹងថាកន្លែងដែលគាត់នៅនោះនៅឯណា ។*

*សហចៅក្រមទី១៖ ត្រូវហើយ ។*

*សារ៉ារី (អត់ធ្មត់មែនទែន)៖ ប្រហែលជាខ្ញុំអាចជួយពួកលោករក "កន្លែងនោះ" ឃើញ ប្រសិនបើលោកប្រាប់ខ្ញុំថាកំពុងរកអ្នកណា ។*

*សហចៅក្រមទី១ (គ្រេកអរ)៖ ពួកខ្ញុំកំពុងរកសាក្សីឈ្មោះ សារ៉ារី ។*

*ឈប់បន្តិច*

*សារ៉ារី៖ នេះហើយ សារ៉ារី ។*

*សហចៅក្រមទាំងពីរមើលជុំវិញ ។*

*សារ៉ារី (បញ្ជាក់)៖ ខ្ញុំហ្នឹងហើយ ។*

*សហចៅក្រមទី១ (ចោទបន្ទោស)៖ ពួកយើងកំពុងតែដើររកមីងហ្នឹងណា៎*

*សារ៉ារី៖ ខ្ញុំនៅនេះរហូតមកហ្នឹង ។*

*សហចៅក្រមទី២៖ នៅយូរប៉ុណ្ណាហើយ?*

*សារ៉ារី (កាច់វាងបន្តិច)៖ ប្រហែល៣០ឆ្នាំ--*

*សហចៅក្រមទី២ (លែងស្តាប់ កាត់សម្តីសារ៉ារី)៖ វាត្រូវតែអ៊ីចឹងហើយ ពួកខ្ញុំបានស្វែងរកមីងអស់រយៈពេលយូរដែរហើយ ។ ពួកខ្ញុំមានការលំបាកខ្លាំងណាស់ក្នុងការដើររកមីង ។*

*សារ៉ារី៖ អ៊ីចឹង...ខ្ញុំអរគុណហើយ ។*

*សហចៅក្រមទី១៖ មិនបាច់គួរសមទេ ។*

*សារ៉ារី៖ ខ្ញុំសូមសួរបានទេ លោករកខ្ញុំមានការអ្វី?*

សហចៅក្រមទី២៖ មកពីមីងអាចជាសាក្សីសំខាន់ម្នាក់ ។

សាក្សី៖ ថាម៉េច ចាស៎?

សហចៅក្រមទី១ (ចូលជ្រៀតជ្រែក)៖ មិនចាំបាច់សុំទោសទេ ។ ថ្វីបើពួកខ្ញុំជួបប្រទះការលំបាកខ្លាំងក្នុងការស្វែងរកមីងយ៉ាងណាក៏ដោយ ក៏មិនអីដែរ ។

សាវរី៖ មិនមែនទេ ខ្ញុំចង់និយាយថាខ្ញុំមិនយល់ ។ ហេតុអ្វីបានពួកលោករកខ្ញុំ?

សហចៅក្រមទី២៖ ពួកខ្ញុំកំពុងតែស៊ើបអង្កេត!

សហចៅក្រមទី១៖ ពួកខ្ញុំជាចៅក្រមស៊ើបអង្កេត!

សហចៅក្រមទី២៖ ពួកខ្ញុំកំពុងតែប្រមូលភស្តុតាងដែលមានសារៈសំខាន់ ដើម្បីយកទៅប្រើប្រាស់នៅក្នុងតុលាការកាត់ទោសមេខ្មែរក្រហម ។

សហចៅក្រមទី១៖ សំខាន់ខ្លាំងមែនទែន

សាវរី៖ ខ្ញុំចង់ជួយលោក ប៉ុន្តែ ខ្ញុំមិនដឹងថាខ្ញុំអាចជួយបានឬអត់ទេ ។ ខ្ញុំមិនដឹងថាលោកចង់បានអីទេ ។

សហចៅក្រមទី១៖ អ៊ូ ។ បើអីចឹង ពួកខ្ញុំនឹងត្រូវទៅហើយ ។

*គាត់បម្រុងនឹងត្រឡប់ទៅវិញ ។*

សហចៅក្រមទី២ *(និយាយទៅកាន់សហចៅក្រមទី១)*៖ ឈប់សិន! *(និយាយទៅកាន់សាវរី)* ពួកខ្ញុំមានសំណួរដែលចង់ឲ្យមីងឆ្លើយ ។

សហចៅក្រមទី១ (ឈប់នៅនឹងកន្លែងគាត់ដើរ)៖ មែនហើយ ។ ពួកខ្ញុំមានសំណួរ ។

សហចៅក្រមទី២៖ ត្រូវហើយ ។ មានសំណួរច្រើនណាស់ ។

សហចៅក្រមទី១៖ ដើម្បីសួរមីង ។

សហចៅក្រមទី២៖ អំពីបទពិសោធន៍របស់មីង ។

សហចៅក្រមទី១៖ សំណួរសំខាន់ៗណាស់ ។

សហចៅក្រមទី២៖ សូមអញ្ជើញអង្គុយ ។

សហចៅក្រមទី១៖ ឆ្លើយឲ្យបានក្បោះក្បាយ ពេញលេញតាមតែមីងអាចឆ្លើយបាន ។

សហចៅក្រមទី២៖ សូមចងចាំថា ចម្លើយរបស់មីងអាចមានសារៈសំខាន់ដល់សវនាការចុងក្រោយបង្អស់ ។

*សាវរីអង្គុយទល់មុខនឹងសហចៅក្រម ។ សហចៅក្រមទាំងពីរនៅតែឈរ មើលចុះមកសាវរី ។ ប្រសិនជាអាចធ្វើបាន បន្ថយភ្លើងឲ្យងងឹត ទុកតែពន្លឺមួយកន្លែងឲ្យភ្លឺចំសាវរី ។ សម្លេងរបស់ចៅក្រមប្តូរទៅជាសម្លេងស្មើ ។ អង្គការដែលមានពាក់របាំងមុខ ដើរចេញមកយឺតៗ ខណៈពេលដែលសាវរីកំពុងឆ្លើយសំណួរ ។ អង្គការដើរលេបៗនៅផ្នែកខាងក្រោយសាវរី នៅពេលសហចៅក្រមសួរគាត់ ។ ភ្លេងលេងសម្លេងស្គរតិចៗ ។*

**សហចៅក្រមទី១៖** *តើមីងបានជួបអង្គការនៅពេលណា?*

**សហចៅក្រមទី២៖** *មិនត្រូវសួរសំណួរនាំមុខ នៅដំណាក់កាលស្ទាបស្ទង់ទេ*

**សហចៅក្រមទី១៖** *តើមីងធ្លាប់ជួបអ្នកណាម្នាក់ទេ?*

**សាវរី៖** *ជួបអ្នកណាម្នាក់? ខ្ញុំហ្នឹងធ្លាប់ជួបអង្គការដែរឬទេអ្ហេ? អត់ទេ ប្រាកដជាមិនដែលជួបហើយ ។ គ្មានអ្នកណាម្នាក់បានជួបអង្គការទេ ។ អ្នកមិនអាចជួបអង្គការបានទេ ។ អង្គការ ។ អង្គការអត់មានទេ ។ អង្គការគ្មានមុខមកឲ្យជួបស្វាគមន៍ទេ ។ អង្គការគ្មានដៃឲ្យយើងចាប់ទេ ។ មានតែប្រជាជន ។ ជួនកាល ប្រជាជនជាអ្នកទទួលបញ្ជា ។ ជួនកាល ប្រជាជនជាអ្នកដែលចេញបញ្ជា ។ ជួនកាល ជាប្រជាជនហ្នឹង ។ ហេតុអ្វីបានលោកសួរខ្ញុំអ៊ីចឹង? គ្រប់គ្នា អ្នកណាក៏ដឹងរឿងនេះដែរ ។*

**សហចៅក្រមទី១៖** *តើអ្នកណាដែលជាអ្នកចេញបញ្ជា?*

**សហចៅក្រមទី២៖** *កុំសួរសំណួរនាំមុខ ក្នុងដំណាក់កាលស្ទាបស្ទង់ ។*

**សហចៅក្រមទី១៖** *តើមីងធ្លាប់ឃើញអ្នកណាម្នាក់ដែលចេញបញ្ជាដែរឬទេ?*

**សាវរី៖** *ចាំ*

**សហចៅក្រមទី២៖** *អ្នកណា?*

*សាវរីបិទភ្នែកហើយឱនក្បាលចុះ ។*

**សហចៅក្រមទី២៖** *នេះជារឿងសំខាន់ ។ មានសារៈសំខាន់ចំពោះប្រទេសរបស់អ្នក ។ ដើម្បីយុត្តិធម៌ ។*

**សាវរី៖** *ខ្ញុំមិនដឹងថាលោកចង់ឲ្យខ្ញុំនិយាយអ្វីប្រាប់លោកទេ ។ រឿងរ៉ាវដែលបានកើតឡើងចំពោះខ្ញុំ និងគ្រួសាររបស់ខ្ញុំ ក៏បានកើតឡើងចំពោះគ្រប់គ្នាដែរ ។ អ្នកនៅភូមិខ្ញុំម្នាក់ៗអាចនិយាយរឿងរ៉ាវរបស់ខ្លួន*

ប្រាប់លោកបានគ្រប់គ្នា ។ ហេតុអ្វីបានជាលោកមិនសួរគេគ្រប់គ្នា? ហេតុអ្វីបានជាលោកមកកន្លែងនេះ សួរតែខ្ញុំ?

*សហចៅក្រមទី២៖* ពួកខ្ញុំមិនមែនស្វែងរករឿងរ៉ាវប្រវត្តិសាស្ត្រទេ ។ ពួកខ្ញុំកំពុងតែរកភស្តុតាង ។ ពួកខ្ញុំមានរឿងដែលត្រូវការភស្តុតាងដើម្បីយកមកបញ្ជាក់បង្ហាញ ។

*សហចៅក្រមទី១៖* រឿងនោះត្រូវដាក់បញ្ចូលគ្នាតាមលក្ខណៈលំដាប់លំដោយឲ្យបានត្រឹមត្រូវ

*សហចៅក្រមទី២៖* តាមទំរង់បែបបទ ។ ជាសំណុំរឿង ។ ជាភស្តុតាង ។

*សហចៅក្រមទី១៖* ដើម្បីយកទៅប្រើជាភស្តុតាង ។

*សហចៅក្រមទី២៖* ពួកខ្ញុំកំពុងតែស្វែងរកចំណែកភស្តុតាង ដែលនឹងអាចបញ្ជាក់បានឬមិនបាន អំពីការកើតឡើងនៃឧក្រិដ្ឋកម្មនោះ ។

*សហចៅក្រមទី១៖* ចំណុចនីមួយៗ

*សហចៅក្រមទី២៖* នៃបទឧក្រិដ្ឋ ត្រូវតែមានភស្តុតាងបង្ហាញឲ្យឃើញនូវគ្រប់តាមចំណុចទាំងអស់នោះ ។

*សហចៅក្រមទី១៖* ដើម្បីបញ្ជាក់ថាឧក្រិដ្ឋកម្មនោះបានកើតឡើងឬអត់ ។

*សហចៅក្រមទី២៖* ដើម្បីបញ្ជាក់ថា ចុងចោទបានប្រព្រឹត្តបទឧក្រិដ្ឋនោះ ។

*សហចៅក្រមទី១៖* ដើម្បីបញ្ជាក់ថា បទឧក្រិដ្ឋនោះចូលក្នុងដែនសមត្ថកិច្ចរបស់តុលាការ ។

*សហចៅក្រមទី២៖* ប៉ុន្តែ មិនបាច់បារម្ភពីរឿងហ្នឹងទេ ទុកឲ្យពួកខ្ញុំខ្វល់វិញ ។

*សហចៅក្រមទី១៖* មីងគ្រាន់តែឆ្លើយសំណួររបស់ពួកខ្ញុំទៅបានហើយ ។

*សាវរី៖* ចុះប្រសិនបើខ្ញុំឆ្លើយ តើនឹងមានអ្វីកើតឡើង?

*សហចៅក្រមទី១៖* អឺ ប្រហែលគ្មានអ្វីទេ ។

*សហចៅក្រមទី២* (សម្លឹងមើលចៅក្រមទី១)៖ ពួកខ្ញុំនឹងថតអាត់សម្លេងដែលមីងនិយាយ ដោយប្រុងប្រយ័ត្ន ព្រោះវានឹងក្លាយជាផ្នែកមួយនៃឯកសារដ្ឋវការ ។ អ្វីដែលមីងនិយាយនឹងត្រូវយកទៅដាក់ក្នុងសំណុំរឿងដែលនឹងក្លាយជាភស្តុតាង ។ (ធ្វើរាងក្រអើតបន្តិច) ថាមិនបាន មីងអាចត្រូវហៅទៅភ្នំពេញ ដើម្បីធ្វើជាកសិណសាក្សីនៅក្នុងពេលមានបណ្តឹងតុលាការ ។

*សាវរី៖* ទៅភ្នំពេញ? ដើម្បីធ្វើសាក្សីឆ្លើយបំភ្លឺ? ខ្ញុំអាចធ្វើដូច្នោះបានដែរ?

*សហចៅក្រមទី២៖* ប្រហែលជាអាចបាន ប្រសិនបើចៅក្រមអ្នកកាត់សេចក្តី មានសំណួរសួរមីង

*សាវរី៖* ប៉ុន្តែ ខ្ញុំមានគ្រួសារ ប្តី កូនចៅ ។ មានការទទួលខុសត្រូវ ។

*សហចៅក្រមទី១៖* អូ៎ ពួកខ្ញុំនឹងរៀបចំចាត់ចែងគ្រប់យ៉ាង ។

*សាវរីៈ ប៉ុន្តែ អ្នកដែលលោកសួរខ្ញុំនោះ គេរស់នៅទីនេះ ។ (ធ្វើឥរិយាបថ) ខ្ញុំខ្លាច ។*

*សហចៅក្រមទាំងពីរមើលមុខគ្នា ហើយមើលទៅសាវរីក្នុងពេលជាមួយគ្នា ។*

*សហចៅក្រម (ទាំងពីរ)ៈ ពួកខ្ញុំនឹងចាត់ចែងទាំងអស់ ។*
*សហចៅក្រមទី២ៈ នីតិវិធីដើម្បីធានាដល់ការការពារសុវត្ថិភាពរបស់មីង បានត្រៀមរួចរាល់ហើយ ។*
*សហចៅក្រមទី១ៈ ដើម្បីលាក់អត្តសញ្ញាណរបស់មីង ។*
*សហចៅក្រមទី២ៈ ប្រសិនបើមីងត្រូវហៅទៅបំភ្លឺ ។*

*ទាំងអស់គ្នាចូលទៅក្រោយឆាក ។*

## ឈុតទី២:

*ព្រះរាជអាជ្ញា មេធាវីការពារចុងចោទ និង ចៅក្រមកាត់ក្តី ដើរចូលឆាក ឈរនៅជ្រុងទល់មុខឆាក មើលទៅអ្នកទស្សនា ។*

*ចៅក្រមៈ ចាំមើលទៅមើល យើងមានអ្វីខ្លះ ។ ភាគីទាំងអស់មានសំណុំឯកសារដែលចៅក្រមស៊ើបអង្កេតបានរៀបចំឲ្យគ្រប់គ្នាហើយមែនទេ?*
***ព្រះរាជអាជ្ញានិងមេធាវីចុងចោទៈ** បាទ ចា៎ មានហើយ ។*
*ចៅក្រមៈ ការកាត់សេចក្តីនឹងចាប់ផ្តើមឆាប់ៗនេះ ។ សាក្សីដែលត្រូវមកបំភ្លឺនៅតុលាការត្រូវបានជ្រើសរើសហើយ ។ ព្រះរាជអាជ្ញា ចង់ស្នើសាក្សីបន្ថែមទៀតទេ?*
***ព្រះរាជអាជ្ញាៈ** ចៅក្រមជាទីគោរព អត់មានទេ ។*
*ចៅក្រមៈ មេធាវីខាងចុងចោទ តើចុងចោទចង់ហៅសាក្សីណាផ្សេងទៀតទេ?*
*មេធាវីៈ ចៅក្រមជាទីគោរព អត់មានទេ ។*
*ចៅក្រមៈ អង្គភាពការពារសាក្សីនឹងរៀបចំចាត់ចែងការធ្វើដំណើរនិងកន្លែងស្នាក់នៅ ។ ពីរសប្តាហ៍ក្រោយ យើងនឹងប្រជុំម្តងទៀតនៅម៉ោង៨ព្រឹក ដើម្បីទុករយៈពេលពីរសប្តាហ៍រៀបចំនីតិវិធី ។ សូមចងចាំថា សហគមន៍អន្តរជាតិកំពុងតែពិនិត្យមើលដំណើរក្តីយ៉ាងហ្មត់ចត់ ។*

## **ឈុតទី៣៖** *សាលសវនាការ*

*សាវរីដើរចូលទៅបន្ទប់តុលាការដោយមានព្រះរាជអាជ្ញាអមដំណើរគាត់ ។ ព្រះរាជអាជ្ញានាំគាត់ដើរទៅខាងឆ្វេង ។*

**ព្រះរាជអាជ្ញា៖** មីងត្រូវនៅក្នុងបន្ទប់រង់ចាំនេះ រហូតទាល់តែគេហៅមីង ។ ប្រហែលជាមិនយូរប៉ុន្មានទេ ។

**សាវរី៖** ខ្ញុំមិនអាចមើលបានទេអ្ហេ?

**ព្រះរាជអាជ្ញា៖** អត់ទេ មើលមិនបានទេ ទាល់តែមីងឡើងបំភ្លឺហើយសិន ទើបមើលបាន បើមិនដូច្នេះទេ វាអាចធ្វើឲ្យជះឥទ្ធិពលដល់ការឆ្លើយរបស់មីង ។ មីងយល់ទេ ។

**សាវរី៖** មិនអីទេ អ៊ីចឹង ខ្ញុំនឹងចាំនៅទីនេះ ។

**ព្រះរាជអាជ្ញា៖** ខ្ញុំនឹងមកនាំមីងទៅ នៅពេលគេហៅមីងឲ្យឡើងឆ្លើយ ។ កុំបារម្ភអី អត្តសញ្ញាណរបស់មីងនឹងត្រូវបានការពារ ពេលនៅក្នុងបន្ទប់តុលាការ ។ នឹងគ្មានអ្នកណាស្គាល់មីងទេ ។

*គាត់អង្គុយចាំនៅលើដី ។ ព្រះរាជអាជ្ញាដើរចូលទៅសាលសវនាការ ហើយអង្គុយនៅកន្លែងតុរបស់គាត់នៅជ្រុងប្រឈមមុខនឹងខាងអ្នកការពារចុងចោទ ។*

**ចៅក្រម៖** សូមចុងចោទនិយាយ ។

**មេធាវី៖** តុលាការជាទីគោរព ចុងចោទមិនមានអ៊ីចង់និយាយទេ ។

**សាវរី** (និយាយទៅកាន់ទស្សនិកជនពីខាងឆ្វេងដៃ)៖ ខ្ញុំចង់ដឹងថាអង្គការកំពុងនិយាយអ៊ី ។

**មេធាវី៖** យើងខ្ញុំសូមបន្តទៅដល់ភស្តុតាងតែម្តង ។

**សាវរី** (និយាយខាងឆ្វេង)៖ ខ្ញុំចង់ស្តាប់អង្គការការពារខ្លួនគាត់ ។

*សាវរីដើរទៅរក "ជញ្ជាំង" បន្ទប់សាក្សី ហើយដាក់ត្រចៀកផ្ទៀងនៅនឹងជញ្ជាំងនោះ ។*

**ចៅក្រម៖** ព្រះរាជអាជ្ញា សូមចាប់ផ្តើមសេចក្តីថ្លែងការណ៍ ។

**ព្រះរាជអាជ្ញា៖** សូមអរគុណ តុលាការជាទីគោរព ។

អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទារុណកម្ម ឃាតកម្ម ការធ្វើទុកបុកម្និញលើសាសនា ។ ៣០ឆ្នាំមុន បុរសម្នាក់នេះបានប្រព្រឹត្តអំពើទាំងអស់នេះ ឬបានបង្កឲ្យធ្វើអំពើទាំងអស់នេះឡើង ។ ការកាត់សេចក្ដីនៅថ្ងៃនេះ នឹងសឲ្យឃើញនៅមុខតុលាការនិងប្រទេសនេះថា បុគ្គលនេះត្រូវទទួលខុសត្រូវចំពោះការរងទុក្ខវេទនាដ៏ធំធេងរបស់ប្រជាជនកម្ពុជា ។ មិនមែនត្រឹមតែទទួលខុសត្រូវតាមផ្លូវសីលធម៌នោះទេ ប៉ុន្តែ ត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់ ។

*សាវរី* (និយាយទៅកាន់អង្គការ)ៈ តើការទទួលខុសត្រូវតាមផ្លូវច្បាប់និងសីលធម៌ជារឿងខុសគ្នាយ៉ាងម៉េច? អ្នកឯងបានធ្វើអំពើនេះ ។ អ្នកបានសម្លាប់គ្រួសាររបស់ខ្ញុំ ។ ធ្វើទារុណកម្មប្ដីខ្ញុំ ។ លួចកូនខ្ញុំ ។

*ព្រះរាជអាជ្ញាៈ* អ្នកណាត្រូវទទួលខុសត្រូវតាមផ្លូវសីលធម៌ មិនមែនជាបញ្ហាចោទនៅក្នុងតុលាការនេះទេ ។ តុលាការនេះមានតួនាទីអនុវត្តតាមស្ដង់ដារអន្តរជាតិ ដើម្បីធានាឲ្យបាននូវតុលាការយុត្តិធម៌មួយ ។ ដូច្នេះ នៅក្នុងតុលាការនេះ មានសំណួរជាលក្ខណៈច្បាប់មួយចំនួន ។ ទីមួយ តើកត្តាទាំងឡាយនៃឧក្រិដ្ឋកម្មនោះ មានគ្រប់តាមលក្ខខណ្ឌឬទេ?

*សាវរីៈ* អ្វីដែលខ្ញុំចង់បានពីតុលាការនេះ គឺយុត្តិធម៌ ។ ឲ្យគ្រួសាររបស់ខ្ញុំ ។ ដើម្បីឲ្យខ្ញុំបានស្ងប់ចិត្តខ្លះ ។

*ព្រះរាជអាជ្ញាៈ* យើងត្រូវតែបង្ហាញឲ្យឃើញថា ចុងចោទបានប្រព្រឹត្តអំពើទាំងឡាយដូចដែលបាននិយាយខាងលើ ឬត្រូវទទួលខុសត្រូវចំពោះអ្នកផ្សេងទៀតដែលប្រព្រឹត្ត ។ ទីពីរ យើងនឹងត្រូវបញ្ជាក់ថា រាល់ទង្វើដែលបុគ្គលនេះបានប្រព្រឹត្ត គឺបំពេញគ្រប់លក្ខខណ្ឌនៃអំពើឧក្រិដ្ឋដែលត្រូវចោទប្រកាន់ ។

*សាវរីៈ* នេះគឺជាយុត្តិធម៌អ្វេ?

*ព្រះរាជអាជ្ញាៈ* ខ្ញុំសូមឲ្យអ្នកចងចាំថា អ្នកដែលត្រូវឡើងសវនាការសាកសួរនៅទីនេះ ថ្ងៃនេះ មិនមែនជាខ្មែរក្រហមទេ ។ ចុងចោទនោះ កំពុងតែត្រូវឡើងសវនាការដើម្បីសាកសួរ ។ ដូច្នេះ យើងមិនត្រឹមតែត្រូវបង្ហាញឲ្យឃើញថា របបខ្មែរក្រហមចូលក្នុងឧក្រិដ្ឋកម្មក្នុងប្រទេសនិងអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែ ត្រូវបង្ហាញថា ជនជាប់ចោទនេះ គឺបុរសដែលអង្គុយនៅនឹងមុខយើងថ្ងៃនេះ បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នោះ ។ យុត្តិធម៌ជារឿងពិបាកយល់ ។ អ្វីដែលយើងស្វែងរកបាននៅទីនេះ គឺការពិត ។

*សាវរីៈ* ខ្ញុំដឹងការពិត ។ ខ្ញុំចង់ឲ្យការពិតត្រូវបាននិយាយប្រាប់ ។ ខ្ញុំចង់ប្រាប់ការពិត ។

*ចៅក្រមៈ* សាក្សីឡើងមកបំភ្លឺ ។

*ព្រះរាជអាជ្ញាដើរឆ្លងទៅរកសាវរី បើកទ្វារ ហើយឲ្យរបាំងមុខមួយទៅគាត់ ។ គាត់ឈរ យកដៃត្រឡប់របាំងមុខនោះមុននឹងពាក់ ។ គាត់ដើរកាត់ទៅកន្លែងសាក្សី ។ គាត់ឈប់ នៅពេលដើរកាត់អង្គការ ។*

*គាត់និងអង្គការសម្លឹងមើលគ្នាទៅវិញទៅមកមួយសន្ទុះ ។ សាវរីនិងអង្គការងក់ក្បាលដាក់គ្នា ។ សាវរីដើរចេញ ហើយឈានជើងចូលឈរកន្លែងសាក្សី ។*

**ចៅក្រមៈ** តើអ្នកស្បថប្តេជ្ញាថានឹងនិយាយការពិតនៅមុខតុលាការនេះទេ?
**សាវរីៈ** ខ្ញុំមិនដែលកុហកអំពីអង្គការទេ ។ (នៅស្ងៀម) ខ្ញុំនៅស្ងាត់ស្ងៀមអស់៣០ឆ្នាំមកហើយ ពីព្រោះគ្មានអ្នកណាសួរ ប៉ុន្តែ ខ្ញុំមិនដែលកុហកទេ ។
**ចៅក្រមៈ** តើអ្នកស្បថសច្ចាទេ--
**សាវរីៈ** ចា៎ ខ្ញុំស្បថ ។
**ចៅក្រមៈ** ខ្ញុំនឹងសួរសំណួរខ្លះទៅអ្នក ។ សូមឆ្លើយឲ្យបានក្បោះក្បាយ ។ បន្ទាប់មក ព្រះរាជអាជ្ញា និង មេធាវីការពារចុងចោទ នឹងមានឱកាសសួរសំណួរអ្នកបន្ថែមទៀត ។ តើអ្នកយល់ឬទេ?
**សាវរីៈ** ខ្ញុំយល់ ។ ខ្ញុំចង់ឆ្លើយសំណួររបស់លោក ។

*នៅឯតុរបស់អ្នកការពារក្តី អង្គការពិនិត្យ ។ គាត់ឈរសំកុក ។ គ្មាននរណាចាប់អារម្មណ៍នឹងគាត់ទេ មានតែ សាវរី កំពុងមើលគាត់មិនដាក់ភ្នែក ។*

**ចៅក្រមៈ** នៅពីមុខរបស់ខ្ញុំមានសំណុំឯកសារដែលនៅក្នុងនោះ មានអំណះអំណាងដែលអ្នកផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេត ព្រមទាំង(ប្រតិចារឹកនៃ)បទសម្ភាសជាអក្សររបស់អ្នកជាមួយសហព្រះរាជអាជ្ញា--

*ចៅក្រមចេះតែបន្តនិយាយដូច្នេះដោយស្ងាត់ៗពីក្រោយសាវរី ។ សាវរីមើលទៅអង្គការរហូតពេលដែលគាត់និយាយ ។ អង្គការនៅតែឈរដដែល ។*

**សាវរីៈ** ខ្ញុំបានរង់ចាំឲ្យគេមកសួរខ្ញុំអស់៣០ឆ្នាំហើយ ។ ខ្ញុំបានរង់ចាំជួបលោកអស់រយៈពេល៣០ឆ្នាំ ។ ខ្ញុំបានរង់ចាំយុត្តិធម៌អស់៣០ឆ្នាំមកហើយ ។ ហើយយើងបានមកដល់កន្លែងនេះ ។
**ចៅក្រមៈ** នៅទំព័រទី៣៨នៃបទសម្ភាសន៍ជាអក្សររបស់អ្នក អ្នកបាននិយាយថា មេដឹកនាំសហករណ៍ទទួលបញ្ជាពី...

*សាវរីៈ លោកមានមេធាវីការពារលោក មានច្បាប់ មានសិទ្ធិ ។ ខ្ញុំគិតថាលោកត្រូវតែមានទាំងអស់នេះទៅចុះ ។ ប៉ុន្តែ គ្មានមេធាវីណាមកការពារកូនៗរបស់ខ្ញុំទេ ។ លោកសម្លាប់ពួកគេទាំងអស់ ។ ប្តីរបស់ខ្ញុំគ្មានសិទ្ធិអ្វីទេ នៅពេលដែលលោកយកគាត់ទៅ ។ (នៅស្ងៀម) ខ្ញុំចង់បានយុត្តិធម៌ ។ ខ្ញុំចង់បានសន្តិភាព ។*

*អង្គការមិនតបតអ្វីទេ ។ គាត់ងាកក្បាលយឺតៗ មើលជុំវិញបន្ទប់តុលាការ ។*

*ចៅក្រមៈ ដើម្បីបញ្ជាក់ឲ្យច្បាស់ គឺនៅពេលដែលអ្នកនិយាយថា អ្នកបានឃើញការប្រហារជីវិតរបស់...*

*សាវរីៈ ប៉ុន្តែ ខ្ញុំមិនអាចធ្វើអ្វីបានក្រៅពីគិតថា យុត្តិធម៌គឺនឹងត្រូវកាត់ទោសលោកឯងដោយច្បាប់របស់លោកឯងផ្ទាល់ ។ ខ្ញុំចង់ឲ្យលោកសងកូនរបស់ខ្ញុំ សងប្តីរបស់ខ្ញុំ ។*

*ចៅក្រមៈ តើព្រះរាជអាជ្ញាមានសំណួរអីទៀតទេ?*

*ព្រះរាជអាជ្ញាៈ អត់មានទេ តុលាការជាទីគោរព ។*

*ចៅក្រមៈ តើខាងមេធាវីការពារចុងចោទ មានសំណួរអីទេ?*

*មេធាវីៈ បាទ មាន តុលាការជាទីគោរព ។*

*ចៅក្រមៈ សូមអញ្ជើញសួរ ។*

*មេធាវីៈ នៅទំព័រទី៥៧នៃបទសម្ភាសន៍ច្បាប់ដើមរបស់អ្នក អ្នកបានអះអាងថា នៅខែឬប្រហែលជាខែកក្កដា ឆ្នាំ១៩៧៦--*

*សាវរីៈ ពិភពលោកកំពុងតែមើលមកតុលាការនេះ ។*

*(អង្គការងាកមកមើលមុខនឹងសាវរី) ។*

*សាវរីៈ ពិភពលោកកំពុងស្តាប់ ។ បន្ទាប់ពី៣០ឆ្នាំក្រោយមក ប្រទេសរបស់ខ្ញុំកំពុងតែស្តាប់ ។ (នៅស្ងៀម) ខ្ញុំមិនដឹងថាអ្វីជាយុត្តិធម៌ទេ ។ ខ្ញុំមិនដឹងថាយុត្តិធម៌ត្រូវការអ្វីពីយើងទេ ។ ប៉ុន្តែ ប្រហែលជាការប្រសើរដែលយើងអាចធ្វើបាន គឺនិយាយពីរឿងនោះ ។ ប្រហែលជាយុត្តិធម៌កំពុងតែធ្វើដំណើរទៅមុខ ប៉ុន្តែមិនអាចបំភ្លេចបានទេ ។ ប្រហែលជាយុត្តិធម៌តែមួយគត់ដែលមានអត្ថន័យនោះ គឺការបង្កើតសង្គមមួយ ដែលកូនចៅរបស់យើងចង់រស់នៅ ។*

**ចៅក្រមៈ** តើមានសំណួរអីសម្រាប់សាក្សីនេះទៀតទេ?

**មេធាវីៈ** អត់មានទេ តុលាការជាទីគោរព ។

**ចៅក្រមៈ** សាក្សីអាចចេញទៅវិញបានហើយ ។

*សាវរី ឈរប្រឈមមុខនឹងអង្គការដែលកំពុងអង្គុយយឺតៗ ។ គាត់ងាកចេញ ហើយដើរទៅយឺតៗ ដោយមិនងាកក្រោយ ។*

**ចៅក្រមៈ** សូមមេធាវីចុងចោទថ្លែងសរុបសេចក្តី

**មេធាវីៈ** សូមអរគុណ តុលាការជាទីគោរព ។

កាលពី៣០ឆ្នាំកន្លងទៅ នៅក្នុងប្រទេសកម្ពុជា បានកើតមាននូវការរំលោភបំពានសិទ្ធិមនុស្សដ៏ខ្លាំងមួយដែលបានកត់ត្រានៅក្នុងប្រវត្តិសាស្រ្ត ។ គ្មានអ្វីគួរសង្ស័យឡើយ ។ រឿងរ៉ាវដ៏អាក្រក់បានកើតឡើងនៅទីនេះ ហើយយើងនៅតែព្យាយាមក្រោកឡើងពីព្រឹត្តិការណ៍ទាំងអស់នោះ ។ ទោះជាយ៉ាងណាក៏ដោយ ក៏គោលបំណងនៃការកាត់សេចក្តីនេះ មិនមែនដើម្បីបង្ហាញឲ្យឃើញថា ហេតុការណ៍ដ៏អាក្រក់ទាំងនោះ បានកើតឡើងទេ ។ ផ្ទុយទៅវិញ គោលបំណងនៃការកាត់សេចក្តីនេះ គោលបំណងរបស់ការការពារក្តីនេះ គឺមានពីរយ៉ាង ។ ទីមួយ គឺត្រូវបញ្ជាក់ថាតើហេតុការណ៍ដែលបានកើតឡើងបំពេញតាមនិយមន័យស្របនឹងច្បាប់ឧក្រិដ្ឋកម្មដែលចោទដែរឬទេ ។ ទីពីរ ត្រូវកំណត់ថាតើជនជាប់ចោទនេះ គឺបុគ្គលរូបនេះ ត្រូវទទួលខុសត្រូវតាមច្បាប់ ចំពោះទង្វើទាំងអស់នោះទេ ។

ខ្មែរក្រហមមានសុភាសិតមួយនិយាយថា “សូវនាំប្រទ្បំ កុំឲ្យតែលែងប្រទ្បំ” ។ (នៅស្ងៀម) យើងខ្ញុំសូមជំទាស់ទៅនឹងសុភាសិតនេះ ។ យើងខ្ញុំក៏ដូចជាមនុស្សនៅទូទាំងពិភពលោក ភាគច្រើន គឺបានសន្មត់ថាខ្លួនឯងបរិសុទ្ធគ្មានកំហុស ។ ចំពោះមតិដែលថា ដោះលែងមនុស្សមានកំហុសដប់នាក់ឲ្យមានសេរីភាពប្រសើរជាជាងដាក់ទោសមនុស្សគ្មានកំហុសម្នាក់ ។ យុត្តិធម៌គឺជាដំណើរការ ។ តាមរយៈដំណើរការនោះ យើងត្រូវបង្ហាញថាចុងចោទមានកំហុសឬគ្មានកំហុស ។ បើគ្មានដំណើរការនេះទេ ក៏មិនអាចរកការពិតឃើញដែរ ។ គ្មានដំណើរការនេះទេ សេចក្តីសង្ឃឹមដែលយើងរំពឹងទុក គឺជាកំហឹងផងឹតផងុល ដែលនាំទៅដល់ការសងសឹក ។ ក្នុងនាមជាប្រទេសមួយ យើងត្រូវការច្រើនជាងនេះ ។ យើងស្វែងរកយុត្តិធម៌ ។ ហើយអ្នកដែលស្វែងរកយុត្តិធម៌ទាំងអស់ ត្រូវតែស្វែងរកច្បាប់វិន័យ ។

ប្រសិនបើយើងគោរពតាមច្បាប់វិន័យ យើងក៏ត្រូវតែទទួលយកថា ភាគីទាំងអស់ត្រូវតែទទួលបាននូវយុត្តិធម៌ ការកាត់សេចក្តីដោយត្រឹមត្រូវ និង ការសន្មត់ថាគ្មានកំហុស បានដូចគ្នា ។ យើងត្រូវ

តែលះបង់ដើម្បីអនុវត្តតាមច្បាប់វិន័យ មិនថាចុងចោទជាអ្នកណានោះទេ ។ យើងត្រូវតាំងចិត្តដើម្បីឲ្យមានការកាត់សេចក្តីដោយត្រឹមត្រូវចំពោះភាគីគ្រប់រូប មិនមែនតែចំពោះអ្នកដែលយើងអាណិតអាសូរទេ ។ ទោះបីជារឿងនេះពិបាកឲ្យយើងទទួលយកយ៉ាងណាក៏ដោយ គោលបំណងនៃការកាត់សេចក្តីនេះ គឺមិនមែនដើម្បីស្វែងរកយុត្តិធម៌ឲ្យអ្នករងគ្រោះនៃរបបខ្មែរក្រហមទេ ។ គោលបំណងនៃការកាត់សេចក្តីនេះ គឺដើម្បីបញ្ជាក់ឲ្យដឹងថាតើបុរសម្នាក់នេះ គឺតែបុរសនេះម្នាក់គត់ មានកំហុស បានប្រព្រឹត្តបទឧក្រិដ្ឋដូចចោទប្រកាន់ឬទេ ។ គោលបំណងនៃការការកាត់សេចក្តីនេះ គឺដើម្បីឲ្យការកាត់សេចក្តីត្រឹមត្រូវតាមច្បាប់ ។ ដំណើរការកាត់សេចក្តីនេះឯងគឺជាយុត្តិធម៌ ។ សម្រាប់អ្នកដែលត្រូវបានចោទប្រកាន់ និង ចំពោះប្រទេសនេះ ។

តុលាការជាទីគោរព មេធាវីការពារចុងចោទសូមបញ្ចប់សេចក្តី ។

**ចៅក្រមៈ** ចៅក្រមនឹងប្រគល់ឲ្យអង្គជំនុំជម្រះវិនិច្ឆ័យ ។